នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០១/១៨-០៧-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jul-2012, 14:40
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "ការពិនិត្យមើលឡើងវិញនូវឯកសារសម្ងាត់ និង ឯកសារសម្ងាត់បំផុត របស់ ឯ.ខ. គង់ ស្រ៊ឹម ដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង០០១"

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះតុលាការកំពូល: | អង្គបុរេជំនុំជម្រះ |
| លោកស្រី ជា លាង | ចៅក្រម គង់ ស្រ៊ឹម, ប្រធាន | ការិយាល័យសហចៅក្រម |
| លោក Andrew CAYLEY | ចៅក្រម Motoo NOGUCHI | ស៊ើបអង្កេត |
| | ចៅក្រម សោម សិរីវឌ្ឍ | អង្គភាពមេធាវីការពារក្តី |
| | ចៅក្រម A. KLONOWIECKA-MILART | សហមេធាវីការពារក្តីរបស់ |
| | ចៅក្រម ស៊ីន វិទ្ធ | កាំង ហ្គេចអ៊ាវ |
| | ចៅក្រម C. N. JAYASINGHE | អង្គភាពការពារជនរងគ្រោះ |
| | ចៅក្រម យ៉ា ណារិន | អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ |
| | | សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី |

អង្គភាពគ្រប់គ្រងតុលាការ
ប្រធានស្តីទី និងអនុប្រធានរដ្ឋបាល
តុលាការ

១- ជាការឆ្លើយតបទៅនឹងអនុស្សរណៈអន្តរការិយាល័យរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២ ស្តីពី *"ការពិនិត្យមើលឡើងវិញនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុត ដែលស្ថិតនៅក្នុងសំណុំឯកសារនៃសំណុំរឿង០០១"* ("អនុស្សរណៈ") សហព្រះរាជអាជ្ញា តាមការឆ្លើយតបនេះ សូមផ្តល់ការយល់ឃើញដូចតទៅ[1]។

២- ជាវិធីសាស្ត្រទូទៅ សហព្រះរាជអាជ្ញាជឿជាក់ថា តម្លាភាពអតិបរមាដែលអាចមាន និងការអាច ចូលមើលបាន នៅក្នុងកាលៈទេសៈនេះ គួរតែមានគោលបំណងនៃដំណើរការធ្វើកុំឱ្យមានចំណាត់ថ្នាក់។ សេចក្តីណែនាំអនុវត្តស្តីពី *ចំណាត់ប្រភេទ និង ការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង* ("សេចក្តីណែនាំអនុវត្ត") ក៏បានទទួលស្គាល់ផងដែរនូវ "តម្រូវការទាមទារឱ្យមានតុល្យភាពរវាងការ សម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ និងផ្នែកផ្សេងៗទៀតនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការដែលមិនបើកចំហដល់សាធារណជន ជាមួយនឹងតម្រូវការដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធីសាធារណៈ និងសម្រាប់គោលបំណងនៃការអប់រំ និងកេរ្តិ៍ដំណែល"[2]។

៣- ជារួម សហព្រះរាជអាជ្ញាសូមឯកភាពជាមួយនឹងនីតិវិធីដែលបានស្នើសុំដូចដែលបានលើកឡើងយ៉ាងច្បាស់នៅក្នុងកថាខណ្ឌទី៤នៃអនុស្សរណៈ។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាទាមទារសុំឱ្យធ្វើការបញ្ជាក់បំភ្លឺមួយចំនួនស្តីពីកម្រិតដែលអង្គជំនុំជម្រះតុលាការកំពូលមានបំណងចង់ប្រើប្រាស់ នូវការកោសលុបដើម្បីធ្វើឱ្យឯកសារទាំងឡាយដែលនៅក្នុងនោះ មានការសម្ងាត់មានកម្រិត ឬសម្ងាត់បំផុត ក្លាយទៅជាសមស្របសម្រាប់ចេញផ្សាយ។ ដើម្បីជាផលប្រយោជន៍ដល់ការធ្វើឱ្យមានតម្លាភាពជាអតិបរមា និងប្រសិនជាប្រភពនានាអនុញ្ញាតឱ្យនោះ សហព្រះរាជអាជ្ញានឹងគាំទ្រឱ្យមានការកោសលុបទូលំទូលាយ ជាជាងរក្សាទុកថាជាប្រភេទហាមឃាត់ ជាពិសេសចំពោះឯកសារទាំងឡាយណាដែលគ្មានប្រើការកោសលុបនោះ ទំនងជានឹងមិនស័ក្តិសមសម្រាប់ផ្សព្វផ្សាយជាសាធារណៈទេនៅពេលអនាគតខ្លីខាងមុខនេះ (ដូចដែលត្រូវបានធ្វើការជំទាស់នៅក្នុងសេចក្តីសន្និដ្ឋាន អំពីដំណើរការនីតិវិធីរបស់អវតក ដែលត្រូវធ្វើជាបន្តទៀត) ដោយសារមានព័ត៌មាននៅក្នុងឯកសារទាំងនោះ។

៤- មាត្រា៩.២ នៃសេចក្តីណែនាំអនុវត្តទទួលស្គាល់សមត្ថភាពរបស់អង្គជំនុំជម្រះ ដើម្បីបង្គាប់ឱ្យចេញនូវឯកសារដែលបានធ្វើការកោសលុប និងឯកសារសាធារណៈ។ ដើម្បីឱ្យកាន់តែជាក់លាក់ថែមទៀត មាត្រា១២.២(ខ)បានបញ្ជាក់ថា ការកោសលុបគួរតែត្រូវបានប្រើប្រាស់នៅក្នុងដំណើរការទាក់ទងនឹង

---

[1] F30 អនុស្សរណៈ, កថាខណ្ឌទី ២ និង ៥ ។

[2] សេចក្តីណែនាំអនុវត្ត អវតក/០០៤/២០០៩/វិសោធនកម្មលើកទី១, ចំណាត់ប្រភេទ និង ការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង, មាត្រា១.២។

បណ្ណសារដែលអង្គជំនុំជម្រះតុលាការកំពូលត្រូវរៀបចំ ដើម្បីទទួលភារៈចំពោះ៖ "កំណត់ហេតុដែលមានឯកសារសម្ងាត់មួយចំនួនមានកម្រិត ត្រូវតែធ្វើការកោសលុបឲ្យបានត្រឹមត្រូវ ដើម្បីធ្វើឲ្យឯកសារនោះទៅជាសាធារណៈ"។

៥- អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើថា ដំណើរការពិនិត្យឡើងវិញ រួមមានយន្តការសម្រាប់ការកំណត់ថាតើឯកសារណាមួយ ដែលមិនអាចដកចំណាត់ថ្នាក់ចេញ ដែលរួមមាន "ផ្នែកខ្លះនៃឯកសារសម្ងាត់មានកម្រិត" និងអាចដកចំណាត់ថ្នាក់ផ្នែកកោសលុបខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាមានការប្រុងប្រយ័ត្នចំពោះផ្នែកកោសលុបខ្លះ ដែលចាំបាច់ត្រូវដកចេញ មិនត្រឹមតែផ្នែកសម្ងាត់ ឬផ្នែកសម្ងាត់បំផុតនៃឯកសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុញ្ញាតឲ្យអ្នកអាន យល់បានពីបរិបទអង្គហេតុ ដើម្បីកំណត់បានពីខ្លឹមសារនៃផ្នែកសម្ងាត់ ឬផ្នែកសម្ងាត់បំផុត។ ដូចឯកសារនៃសំណុំរឿងទាំងអស់គឺស្ថិតក្នុងទម្រង់ជាអេឡិចត្រូនិចទម្រង់អេឡិចត្រូនិចកោសលុបអាចឲ្យដំណើរការនេះ កាន់តែមានប្រសិទ្ធភាព និងសិក្តិសិទ្ធិតាមដែលអាចធ្វើបាន តាមរយៈការប្រើប្រព័ន្ធ Adobe Software ដែលអាចរកបាននៅតុលាការនេះ។

៦- ជាចុងក្រោយ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ឯកសារសហកាលរបស់កម្ពុជាប្រជាធិតេយ្យ ដែលមានក្នុងសំណុំរឿង គួរតែដកចំណាត់ថ្នាក់ទាំងអស់ ដោយសារឯកសារទាំងនោះ អាចឲ្យគេរកបាន នៅតាមបណ្ណាឃ្លាំងផ្ទុកឯកសារជាសាធារណៈដទៃទៀត ដូចជា DC-Cam ជាដើម។

៧- សហព្រះរាជអាជ្ញាទន្ទឹងរង់ចាំទទួលគោលការណ៍ណែនាំចុងក្រោយដូចបានរំពឹងទុកនេះ អំពីការធ្វើចំណាត់ថ្នាក់ឯកសារជាថ្មី ព្រមទាំងបញ្ជីឯកសារសម្ងាត់ និងសម្ងាត់បំផុត នៅក្នុងសំណុំរឿង០០១។ តាមការណែនាំ សហព្រះរាជអាជ្ញានឹងលើកយោបល់ចាំបាច់បន្ថែមទៀតនៅលើឯកសារ ឬប្រភេទឯកសារណាមួយជាក់លាក់នៅពេលនោះ[3]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១២ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក William SMITH**<br>សហព្រះរាជអាជ្ញារង | | [signature] |

[3] F30 ការពិនិត្យមើលឡើងវិញនូវឯកសារសម្ងាត់ និងឯកសារសម្ងាត់បំផុត នៅក្នុងសំណុំឯកសារនៃសំណុំរឿង០០១, ថ្ងៃទី១១ មិថុនា ២០១២, កថាខណ្ឌទី២។